ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
អគ្គលេខាធិការដ្ឋាន
លេខ ០៤៣ គ.ជ.ប/អគ្គ/ប្រ.ក.ព

ថ្ងៃចន្ទ ១កើត ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០១៨

# សេចក្ដីប្រកាសព័ត៌មាន
## ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៨
## ត្រូវចាប់ផ្ដើមនៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៨

ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៨ នឹងត្រូវចាប់ផ្ដើមពីថ្ងៃទី០១ ដល់ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៨ នេះបើតាមការអះអាងរបស់ឯកឧត្ដម **ម៉ុក ដារ៉ា** អគ្គលេខាធិការរង គ.ជ.ប ក្នុងកម្មវិធីបើកវគ្គបណ្ដុះបណ្ដាលគ្រូបង្គោល និងមន្ត្រី គ.ជ.ប ស្ដីពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៨ នៅសាលសន្និសីទ គ.ជ.ប កាលពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៨។

ឯកឧត្ដម **ម៉ុក ដារ៉ា** បានបន្ថែមថា ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៨ នេះ គឺមានគោលដៅធានាឱ្យបញ្ជីបោះឆ្នោតមានភាពពេញលេញ ភាពត្រឹមត្រូវ និងមានបច្ចុប្បន្នភាពប្រកបដោយសុវត្ថិភាពតាមរយៈ ៖

- ❖ ការស្រង់ និងលុបឈ្មោះអ្នកបោះឆ្នោត ៖
  - ➢ អ្នកដែលបានទទួលមរណភាព
  - ➢ អ្នកដែលត្រូវបានដកហូតនូវសិទ្ធិបោះឆ្នោតជាបណ្ដោះអាសន្ន
  - ➢ អ្នកដែលបានផ្លាស់លំនៅឋាន ឬទីសំណាក់ចេញទៅឃុំ សង្កាត់ផ្សេងដោយមានឯកសារជាសំអាងត្រឹមត្រូវ និងច្បាស់លាស់ ដើម្បីលុបចេញពីបញ្ជីបោះឆ្នោត។
- ❖ ការកែតម្រូវឈ្មោះ ឬទិន្នន័យអ្នកបោះឆ្នោត តាមសំណើសុំរបស់សាមីខ្លួនដោយមានឯកសារសំអាងត្រឹមត្រូវ
- ❖ ការចុះឈ្មោះបោះឆ្នោត សំដៅលើ ៖
  - ➢ ប្រជាពលរដ្ឋខ្មែរដែលមានសិទ្ធិបោះឆ្នោត ហើយមិនទាន់បានចុះឈ្មោះបោះឆ្នោតពីមុនមក
  - ➢ ប្រជាពលរដ្ឋដែលទើបគ្រប់អាយុ ១៨ឆ្នាំ (គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨)
  - ➢ ប្រជាពលរដ្ឋទើបបានផ្លាស់លំនៅឋាន ឬទីសំណាក់ចូលក្នុងឃុំ សង្កាត់ថ្មី ដែលត្រូវចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ដែលសាមីខ្លួនត្រូវបោះឆ្នោត។

បន្ទាប់ពីទទួលបានទិន្នន័យអំពីការចុះឈ្មោះបោះឆ្នោត គ.ជ.ប នឹងរៀបចំជាបញ្ជីបោះឆ្នោតដំបូង ដើម្បីឱ្យប្ដឹងតវ៉ា ឬប្ដឹងជំទាស់ ហើយក្រោយពីបញ្ចប់ការដោះស្រាយពាក្យបណ្ដឹង គ.ជ.ប នឹងផ្ដល់សុពលភាពជាបញ្ជីបោះឆ្នោតផ្លូវការ ឆ្នាំ២០១៨ ។

សូមបញ្ជាក់ថា ការរៀបចំកម្មវិធីបណ្ដុះបណ្ដាលនេះ មានរយៈពេល ៥ ថ្ងៃ ចាប់ពីថ្ងៃទី២៥ ដល់ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨ ដោយមានសិក្ខាកាមចូលរួមចំនួន ៦០នាក់ និងមានគ្រូឧទ្ទេសធ្វើបទបង្ហាញអំពីបទបញ្ញា នីតិវិធីនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ដំណើរការប្រព្រឹត្តទៅនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតព្រមទាំងការប្រើប្រាស់កម្មវិធីចុះឈ្មោះ ។ល។